## របាយការណ៍

## ដែនទីរណ្តៅសាកសពស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង

*ដោយៈ ផេង ពង្សរ៉ាស៊ី*

ឆ្លៀតពេលដែលប្រជាជនខ្មែរទូទាំងប្រទេស កំពុងតែសស្រាក់សស្រាំជញ្ជូនបាយសម្លទៅកាន់វត្តអារាមតាមវេណវៀងៗខ្លួនក្នុងការកាន់បិណ្ឌតាមទំនៀមទំលាប់ប្រពៃណីជាតិខ្មែរ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅកាន់ខេត្តស្វាយរៀង ដើម្បីរំលឹកដល់ការកាប់សម្លាប់មនុស្សនាសម័យខ្មែរក្រហមមកលើប្រជាជនស្លូតត្រង់អស់រាប់លាន់នាក់ និងជាឱកាសមួយក្នុងការជួយក្រើនរំលឹកដល់អ្នកដែលនៅសេសសល់ពីការស្លាប់ដោយស្នាដៃខ្មែរក្រហម ឲ្យនឹកឃើញឡើងវិញនូវការបាត់បង់សាច់ញាតិរបស់ខ្លួនកាលពីរបបដែលគ្រប់គ្រងដោយប៉ុលពត ហើយពិតជាត្រូវបានរំលឹកឡើងនូវឈ្មោះអ្នកដែលបានចែកឋានទៅទាំងនោះ នៅពេលដែលពួកគាត់កំពុងអង្គុយបត់ជើងអុជធូបទានពីមុខព្រះបដិមាករ និងបន់ស្រន់ដល់អ្នកដែលបានស្លាប់ទៅកាលពីជំនាន់ប៉ុលពត សូមឲ្យបានដល់សុគតិភព និងឆាប់ចាប់ជាតិជាមនុស្សវិញដើម្បីឃើញសង្គមជាតិថ្មីមួយដែលគ្មានការកាប់សម្លាប់មនុស្ស គ្មានការធ្វើទារុណកម្មមនុស្ស និងគ្មានការប្រើមនុស្សឲ្យហួសកម្លាំងដូចរបបមុនទៀតឡើយ ។ បើក្រឡេកមើលតាមដងវិថីនានាតាមទីជនបទ ខ្ញុំតែងតែបានប្រទះឃើញមនុស្សម្នាមានស្រីប្រុសចាស់ក្មេងស្ថិតក្នុងសម្លៀកបំពាក់សមរម្យអាវសរ សំពត់ ឬខោខៀវ-ខ្មៅមានប្រដាប់ដោយទានធូប ផ្កាភ្ញី ព្រមជាមួយការយួរស្រាក់ដែលផ្ទុកដោយបាយ សម្ល និងបង្អែមសំដៅទៅកាន់ទីវត្តអារាមដែលពួកគេធ្លាប់ធ្វើបុណ្យ ។ ក្នុងពេលកំពុងធ្វើដំណើរទៅកាន់ខេត្តស្វាយរៀង បូករួមជាមួយការប្រទះឃើញទិដ្ឋភាពបែបនេះ ខ្ញុំហាក់មានអារម្មណ៍មិនធម្មតាទាល់តែសោះ ទោះជាខំបំភ្លេចដោយចាក់ជាចំរៀងស្តាប់បន្ទប់បរិយាកាសយ៉ាងណាក៏ដោយ ក៏នៅតែនឹកឃើញ និងទាញការប្រៀបធៀបជានិច្ចនូវការយួរស្រាក់នេះទៅនឹងមនុស្សម្នាទាំងឡាយក្នុងសម្លៀកបំពាក់ខ្មៅ ប្រដាប់ដោយចង និងបង្គីរ មានក្មេងចាស់ ប្រុសស្រីដើរសំដៅទៅកាន់ការដ្ឋានរៀងៗខ្លួនទាំងក្បាលជន្លង់ធំជាងភ្លៅ បូករួមជាមួយទឹកមុខស្រពាប់ស្រពោនដែលបង្ហាញយ៉ាងច្បាស់ពីភាពគ្មានសង្ឃឹមក្នុងជីវិត ។ ម្យ៉ាងវិញទៀត ភាពពពាក់ពពូនគ្នារាប់បាត្រលោក រិតតែធ្វើឲ្យខ្ញុំនឹកគិតដល់ពីការខំប្រឹងប្រែងកាប់ដីដាក់បង្គីទោះជាមានអ្នកខ្លះត្រូវដួលស្លាប់នៅនឹងកន្លែងក៏ដោយ ហើយរែករត់យ៉ាងលឿនសំដៅទៅចាក់ទំនប់ដែលជាគោលដៅរបស់ខ្លួន ដើម្បីប្តូរមកវិញនូវជីវិតដែលរស់បានមួយថ្ងៃទៀត និងរបបអាហារប្រចាំថ្ងៃរបស់ខ្លួនផង ។ គិតសព្វៗទៅ ប្រសិនបើរបបកម្ពុជាប្រជាធិបតេយ្យដែលគ្រប់គ្រងដោយសាឡុត ស ហៅប៉ុលពតនេះ នៅតែបន្តយូរអង្វែងទៀត តើពិតជាមានមនុស្សម្នាច្រើនបែបនេះ មកដាក់បិណ្ឌបញ្ជូនកុសលឲ្យបុព្វការីជនដែលបានស្លាប់ទៅដែរឬទេ? ។ តើពួកគាត់ដែលកំពុងយួរចានស្រាក់ដើរតម្រង់

ទៅកាន់ទីអារ៉ាម មានបានគិតដល់ស្រមោលអតីតកាលរបស់ខ្លួនដែលធ្លាប់បានឆ្លងកាត់សម័យប៉ុលពតដូចខ្ញុំដែរ ឬទេ? ។

ទឹកដីភូមិត្រពាំងត្រាច ដែលមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម បច្ចុប្បន្នត្រូវទទួលរងនូវគ្រោះរាំងស្ងួត ។ សន្ទូង សំណាបត្រូវក្រៀមស្វិតដោយគ្មានទឹក ។ ប្រជាកសិករទាំងឡាយបានពឹងផ្អែកទាំងស្រុងទៅលើកសិកម្មដែលប្រវ៉ាសដៃជាមួយមេឃ ជាមួយព្រហ្មលិខិត ។ គ្មានមធ្យោបាយនឹងពង្រីកមុខរបរធ្វើស្រែនេះឲ្យជឿនលឿនបានឡើយ ប្រសិនបើជីវភាពប្រជាជននៅតែក្រីក្របែបនេះ ។ ប៉ុន្តែជាចៃដន្យមួយដ៏ប្រពៃណាស់ ភ្លៀងមួយមេយ៉ាងធំបានបង្អុរចុះមកស្របពេលដែលក្រុមយើងបានធ្វើដំណើរទៅដល់ទឹកដីភូមិត្រពាំងត្រាច ឃុំស្វាយតាយាន ស្រុកកំពង់រោទ៍ ។ ប្រជាកសិករបានអបអរសាទរនឹងតំណក់ទឹកភ្លៀងដែលធ្លាក់ចុះនេះ មើលចុះអ្នកខ្លះបានមកស្ទូងសំណាបទាំងកណ្តាលភ្លៀងធ្លាក់ ខ្លះទៀតឈរត្រងទឹកដាក់ពាងដែលធ្លាប់តែរីងស្ងួតជាយូរណាស់មកហើយ ។ ប៉ុន្តែផ្ទុយទៅវិញ ជាប្រការមួយដ៏អាក្រក់សម្រាប់ក្រុមស្រាវជ្រាវយើងទៅវិញ ។ ផ្លូវដែលក្រាលទៅដោយដីល្បាប់ មិនអនុញ្ញាតិឲ្យរថយន្តរបស់ក្រុមយើងធ្វើដំណើរទៅដោយសុវត្ថិភាពឡើយ ។ ការធ្វើដំណើរទាំងប្រថុយប្រថាន និងស្រពិចស្រពិលទៅកាន់ទីតាំងសម្លាប់មួយដែលមានចម្ងាយប្រហែល៦គីឡូម៉ែត្រពីសាលាឃុំស្វាយតាយានតាមបណ្តោយផ្លូវលំមួយខ្សែនេះ ត្រូវបានផ្អាកដោយសម្រេចចិត្តត្រឡប់មកក្រោយវិញទាំងភ្លៀងកំពុងតែធ្លាក់ ។ ទីតាំងសម្លាប់ទួលយាយខៀវ ត្រូវខកខានមិនបានចុះទៅស្រាវជ្រាវដល់ទីតាំងឡើយ ។ បញ្ហាសន្តិសុខ មិនត្រូវបានភ័យខ្លាចទាំងអស់ក្នុងការចុះស្រាវជ្រាវលើកនេះ ។ លោកអភិបាលរងស្រុកកំពង់រោងទ៍ក៏បានជូនដំណើរក្រុមយើងក្នុងការធ្វើការងារដែរ ។

ក្នុងការចុះទៅស្រាវជ្រាវនៅស្រុកកំពង់រោទ៍លើកនេះ ក្រុមយើងបានមានគោលបំណងចង់សិក្សាទៅលើទីតាំងចំនួនពីរគឺទីតាំងសន្តិសុខនៅភូមិត្រពាំងត្រាច និងទីតាំងសម្លាប់ទួលយាយខៀវ ។

១) មន្ទីរសន្តិសុខភូមិត្រពាំងត្រាច លេខកូតភូមិសាស្ត្រ:២០០២០៥

**(N) 11º 00' 53:52"** **(E) 105º 59' 04:78"**

ភូមិព្រៃប្រីសជាឈ្មោះដើមនៃភូមិត្រពាំងត្រាច ។ កាលពីសម័យខ្មែរក្រហមកាន់អំណាច ភូមិព្រៃប្រីសនៅតែនិយមហៅពីប្រជាជនគ្រប់ប្រភេទ និងយកមកប្រើជាផ្លូវការក្នុងជំនាន់ប៉ុលពត ។ ប៉ុន្តែដល់បច្ចុប្បន្ននេះត្រូវបានកែប្រែឲ្យទៅជាភូមិត្រពាំងត្រាចវិញ ។ ភូមិត្រពាំងត្រាចស្ថិតនៅក្នុងឃុំស្វាយតាយាន ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។ មន្ទីរសន្តិសុខនៅភូមិត្រពាំងត្រាចត្រូវកំណត់យកផ្ទះប្រជាជនធ្វើជាមន្ទីរឃុំឃាំង ។

អ៊ុក សំ អាយុ៨៧ឆ្នាំ ។ បច្ចុប្បន្នរស់នៅភូមិត្រពាំងត្រាច ឃុំស្វាយតាយាន ស្រុកកំពង់រោទ៍ បានមានប្រសាសន៍ថា ផ្ទះរបស់គាត់ត្រូវខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងមនុស្សមកពីទីក្រុងភ្នំពេញ ។ ការឃុំឃាំងអ្នកទោសមិនត្រូវបានប្រព្រឹត្តិទៅមួយកន្លែងទេ

ផ្ទះអ្នកស្រុកជាច្រើនត្រូវបានយកធ្វើជាមន្ទីរឃុំឃាំង បណ្ដោះអាសន្នរបស់ពួកខ្មែរក្រហម ។ លោកមេភូមិ ភោគ នៅ អាយុ៦២ឆ្នាំ ជាមេភូមិត្រពាំងត្រាច ឃុំស្វាយតាយានបាននិយាយថា "មានផ្ទះចំនួន៨ត្រូវពួកខ្មែរក្រហមយកធ្វើជាគុក ក្នុងនោះមានផ្ទះឪពុកខ្ញុំ ឈ្មោះ សំ, ផ្ទះលោកតាភោគ កុយ, ផ្ទះលោកតាប្រាជ្ញ ផាន់, និងផ្ទះលោកតាគង់" ។ លោកតាអ៊ុក សំ បាននិយាយបន្តថា ក្នុងផ្ទះមួយៗមានដាក់អ្នកទោសពី៥០ទៅ៦០នាក់ ហើយច្រើនតែជាប្រភេទទាហានមកពី ទីក្រុងភ្នំពេញ ។ អ្នកទោសទាំងអស់តម្រូវឲ្យជួយស្ទូងដកជាមួយប្រជាជនមូលដ្ឋាន និងជួយកាប់ឫស្សីនៅពេល ថ្ងៃ ឯពេលយប់ដាប់ខ្នោះនៅក្នុងផ្ទះ ។ ជនរងគ្រោះទាំងអស់ មិនត្រូវទុកនៅឃុំឃាំងយូរឡើយ ។ លោកតាអ៊ុក សំបាននិយាយថា គាត់បានឃើញមានការបណ្ដើរចេញស្ទើរតែរាល់ថ្ងៃនៅវេលាម៉ោង២ឬ៣រសៀល ប៉ុន្តែមិន ដឹងជាបណ្ដើរទៅកាន់កន្លែងណាទៀត ។ លោកតាបានបញ្ជាក់ពីការឃុំឃាំងមេឃុំទាំងអស់នៅក្នុងស្រុកកំពង់រោទ៍ ថាត្រូវពួកខ្មែរក្រហមយកមកឃុំឃាំងនៅក្នុងវត្តព្រៃធ្លកទាំងអស់ ។ លោកពូប្រធានភូមិបានបន្ថែមថាមេសន្តិសុខធំប្រចាំនៅភូមិត្រពាំងត្រាចមានឈ្មោះ ពេជ សាវឿន ។ សាវឿន មានមាឌធំដំបង ខ្មៅ មុខមាត់កាចសាហាវ ព្រៃផ្សៃ ។ គ្មានអ្នកទោស ឬប្រជាជនណាម្នាក់ហ៊ានចូលទៅជិតឡើយ ។ តាមការស្រាវជ្រាវរបស់ក្រុមធ្វើផែនទីកាលពីឆ្នាំ២០០០បានឲ្យដឹងថា ពេជ សាវឿននេះជាប្រធានសន្តិសុខប្រចាំនៅគុកឫស្សីសាញ់ ។ លោកតាអ៊ុក សំ បានចង្អុលបង្ហាញយើងពីប្រហោងចំនួនពីរបីនៅជញ្ជាំងផ្ទះរបស់គាត់ ហើយប្រាប់ថា នេះជាប្រហោងសម្រាប់ដាក់ខ្នោះកាលពីផ្ទះរបស់គាត់ត្រូវយកធ្វើជាមន្ទីរឃុំឃាំង ។

## ទីតាំងសម្លាប់ព្រៃយាយខៀវ

ព្រៃយាយខៀវ ជាព្រៃមួយដែលមានចម្ងាយប្រហែល២គីឡូម៉ែត្រពីភូមិត្រពាំងត្រាច ឃុំស្វាយតាយាន ។ ទីតាំងនេះបច្ចុប្បន្នជាវាលស្រែធំទូលាយមួយដែលគ្មានព្រៃបន្តិចសោះ ផ្ទុយស្រឡះកាលពីជំនាន់ខ្មែរក្រហមនៅកាន់អំណាចដែលមានសុទ្ធតែព្រៃក្រាសឃ្មឹក និងដំបូកខ្ពស់ៗ ។ ខ្មែរក្រហមបានកំណត់យកព្រៃយាយខៀវនេះជាព្រៃសម្រាប់សម្លាប់មនុស្សកាលពីអំឡុងឆ្នាំ១៩៧៥-៧៦ ។ ប្រជាជនភាគច្រើននៅក្នុងភូមិត្រពាំងត្រាច សុទ្ធតែបានដឹងពីការសម្លាប់មនុស្សនៅព្រៃយាយខៀវនេះ ។

លោកតាអ៊ុក សំបានប្រាប់ថា ទួលយាយខៀវជាទីតាំងសម្លាប់ពិតប្រាកដមែន ព្រោះគាត់បានឃើញមានត្បូងចបមួយនៅក្បែរដំបូកក្នុងបរិវេណទួលយាយខៀវ ។ លោកតាប្រាប់ថា ត្បូងចបនោះហើយ ជាត្បូងចបដែលពួកខ្មែរក្រហមសម្លាប់មនុស្ស ។ លោកតាបានឃើញព្រឹត្តិការណ៍នេះនៅឆ្នាំ១៩៧៥ ពេលដែលលោក តាបានត្រឡប់មកផ្ទះកំណើតរបស់គាត់វិញ

បន្ទាប់ពីត្រូវបានជម្លៀសឲ្យទៅនៅតំបន់វាលដាច់ស្រយាលពីភូមិ រួចមក ។ លោកតាបានរៀបរាប់ថា ថ្ងៃមួយនៅពេលដែលគាត់ទៅរកស្លឹកនៅក្បែរទួលយាយខៀវ ស្រាប់តែគាត់ក្រឡេកឃើញមានត្បូងចបមួយដែលមានប្រឡាក់សុទ្ធតែឈាមស្ថិតនៅក្បែរដំបូក ។ គ្រាន់តែឃើញភ្លាម គាត់មានអារម្មណ៍ភ័យរន្ធត់ ហើយលែងហ៊ានលុកចូលទៅរកស្លឹកក្នុងព្រៃយាយខៀវទៀត ព្រោះខ្លាចត្រូវបានសម្លាប់ ។ ម្យ៉ាងក្លិនស្អុយ បានជះក្លិនមកប៉ះច្រមុះលោកតា រិតតែធ្វើឲ្យលោកតាប៉ាន់ស្មានថាពិតជាសាកសពមនុស្សដែលរលួយហើយ ។ លោកពូភោគ នៅ បាននិយាយថា គាត់បានទៅឃើញរណ្តៅនៅពាសពេញតែព្រៃយាយខៀវ ។ មិនតែប៉ុណ្ណោះ លោកពូបានមានប្រសាសន៍ថា មិនត្រឹមតែក្នុងបរិវេណព្រៃយាយខៀវប៉ុណ្ណោះទេ ក្រៅពីកន្លែងនេះក៏មានរណ្តៅដែរ ។ ការសម្លាប់មនុស្សនៅព្រៃយាយខៀវនេះ ប្រព្រឹត្តិទៅនៅឆ្នាំ ១៩៧៥និង១៩៧៦ ។ មនុស្សភាគច្រើននៅភូមិត្រពាំងត្រាច សុទ្ធតែបានដឹងពីការសម្លាប់មនុស្សនៅព្រៃយាយខៀវនេះ ។ រណ្តៅទាំងប៉ុន្មាន បើតាមលោកពូប៉ាន់ស្មានថា មានទំហំទទឹងពីមួយម៉ែត្រទៅមួយម៉ែត្រកន្លះ និងបណ្តោយប្រវែងជង្គង់មនុស្ស ។ ហើយចំនួនជនរងគ្រោះវិញ គឺមានចំនួនប្រហែលពី៧ទៅ៨នាក់ក្នុងមួយរណ្តៅ ។ លោកពូបានប៉ាន់ស្មានថា មានរណ្តៅពី៣០ទៅ៤០រណ្តៅ និងមានផ្ទុកជនរងគ្រោះពី១២០-១៦០នាក់ ។ លោកតាអ៊ុក សំបានសន្និដ្ឋានថា មនុស្សដែលស្លាប់នៅលើទួលព្រៃយាយខៀវនេះ គឺពិតជាសាកសពអតីតទាហានដែលជាប់និន្នាការពីសង្គម ហើយដែលពីមុនពេលសម្លាប់គឺពិតជាបានយកមកដាក់ឃុំឃាំងនៅតាមផ្ទះប្រជាជនក្នុងភូមិត្រពាំងត្រាច ។

មានការគាស់រណ្តៅសាកសពនៅព្រៃយាយខៀវនៅក្នុងឆ្នាំ១៩៨២ -៨៣ដោយរដ្ឋាភិបាល ។ អដ្ឋិធាតុដែលគាស់បាន បានដឹកជញ្ជូនទៅកាន់វត្តព្រៃធ្លក ដើម្បី តម្កល់ទុកជាភស្តុតាងនៃការសម្លាប់មនុស្សនេះ ។ បូជនីយដ្ឋានមួយត្រូវបានសាងសង់ថ្មីនៅវត្តព្រៃធ្លកកាលពីជំនាន់នោះ (ទសវត្សរ៍១៩៨០)សម្រាប់តម្កល់អដ្ឋិធាតុដែលគាស់បាន ។ លោកតាបានរៀបរាប់ពីការគាស់អដ្ឋិធាតុ ថាឃើញមានឆ្អឹងគរជាពំនូកៗជាច្រើនពំនូក ។

## ទីតាំងមិនទាន់ចុះ

តាមសម្តីរបស់លោកពូប្រធានភូមិត្រពាំងត្រាចថាមានទីតាំងចំនួនពីរៈ មួយមានឈ្មោះថាបឹងខ្នាង ។ បឹងខ្នាងនេះជាទីតាំងសម្លាប់មនុស្សកាលពីជំនាន់ប៉ុលពត ។ បឹងខ្នង ស្ថិតនៅក្នុងឃុំស្វាយតាយាន ស្រុកកំពង់រោទ៍ ។ តាមការឲ្យពត៌មានពីលោកពូប្រធានភូមិថាមានតែ៥រណ្តៅទេ ហើយក្នុងមួយរណ្តៅៗមានដាក់សាកសពចំនួនពី២-៤នាក់ ។ ប្រភេទជនរងគ្រោះដែលបានមកស្លាប់នៅទីនោះគឺជាគ្រូ,ទាហានដែលជាប់និន្នាការ

ពីសង្គមចាស់ និងប្រជាជននៅឃុំស្វាយតាយានខ្លះ ។ ទីតាំងនេះ ក្រុមយើងមិនបានចុះទៅទេ ព្រោះស្ថានភាពផ្លូវពិបាកពេក ។ ដល់ខែប្រាំងប្រហែលជាអាចធ្វើដំណើតតាមកង់ ឬម៉ូតូបាន ។

ទីតាំងសម្លាប់មួយទៀតឈ្មោះ ព្រៃថ្វាន់ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិព្រៃភ្លៀត ឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។ លក្ខណៈភូមិសាស្ត្រក្នុងការធ្វើដំណើរទៅកាន់ទីតាំងនេះ គឺមានស្ថានភាពលំបាកឆ្លងកាត់វាលស្រែរាប់ហិកតា ។ បច្ចុប្បន្នទឹកលិច មើលដាច់កន្ទុយភ្នែក ។ ខែប្រាំងអាចធ្វើដំណើរទៅបាន ។

## សន្និដ្ឋានរួម

ការសម្លាប់មនុស្សនៅស្រុកកំពង់រោទ៍ ជាពិសេសភូមិត្រពាំងត្រាច ឃុំស្វាយតាយាន គឺពិតជាបានប្រព្រឹត្តិឡើងតាំងពីឆ្នាំ១៩៧៥មក ។ មានសាក្សីចំនួនពីរនាក់សុទ្ធតែបានបញ្ជាក់ដូចគ្នាថា ការសម្លាប់មនុស្សបានកើតឡើងតាំងពីឆ្នាំ១៩៧៥ ហើយបន្តរហូតដល់ឆ្នាំ១៩៧៦ទៀត ។ មានទីតាំងមួយកន្លែងក្នុងភូមិត្រពាំងត្រាច ត្រូវបានជ្រើសរើសជាមន្ទីរសន្តិសុខរបស់ពួកខ្មែរក្រហមដែលមានឈ្មោះ ពេជ សាវឿនជាអ្នកកាន់កាប់ ហើយផ្ទះប្រជាជនចំនួន៤ខ្នង ត្រូវបានក្លាយជាមន្ទីរឃុំឃាំងបណ្ដោះអាសន្នសម្រាប់អ្នកទោសបន្ទាប់ពីជម្លៀសម្ចាស់ផ្ទះឲ្យទៅកន្លែងផ្សេងមក ។ បច្ចុប្បន្នផ្ទះទាំងនេះមិនត្រូវបានរុះរើធ្វើថ្មីឡើយ ។ តាមការចោទសួរផ្ទាល់មាត់ទៅលើម្ចាស់ផ្ទះនាបច្ចុប្បន្ន សុទ្ធតែឆ្លើយថា “ជាការពិតណាស់ កាលពីជំនាន់ខ្មែរក្រហមផ្ទះនេះជាគុករបស់ខ្មែរក្រហម” ។ អ្នកទោសច្រើនជាប្រភេទទាហាន និងមន្ត្រីរាជការដែលបានជម្លៀសមកពីទីក្រុងភ្នំពេញ ។ ការឃុំឃាំងមនុស្សមិនត្រូវបានពន្យាពេលយូរឡើយ ។ អ្នកទោសទាំងអស់ត្រូវជម្លៀសចេញនៅពេលប្រហែលម៉ោង៧ ឬ៣រសៀល ទៅកាន់កន្លែងមួយដែលគ្មាននរណាដឹង ។ ប៉ុន្តែភាពលាកការណ៍នេះ ត្រូវបានបើកកកាយការពិតកាន់តែច្បាស់ថែមទៀតនៅឆ្នាំ១៩៨២-៨៣ ដោយការជីករណ្ដៅសាកសពនៅព្រៃយាយខ្សៅ ដោយកម្លាំងខាងរដ្ឋាភិបាលកម្ពុជា ក្នុងការស្រាវជ្រាវរកភស្តុតាងក្នុងការកាត់ទោសកាលពីឆ្នាំ១៩៨២ ។ ព្រៃយាយខ្សៅ ជាទីតាំងសម្លាប់ធំប្រចាំឃុំស្វាយតាយាន ។ អ្នកទោសភាគច្រើនជាទាហាន មន្ត្រីរដ្ឋការជំនាន់លន់ណុល និងប្រជាជនសាមញ្ញនៅឃុំស្វាយតាយាន ។ ទីតាំងនេះ សរុបមានចំនួនពីរ៣០-៤០រណ្ដៅនិងមានចំនួនសាកសពប្រហែលពី១២០-១៦០នាក់ ។ ទីតាំងសម្លាប់ព្រៃយាយខ្សៅនេះ ក្រុមស្រាវជ្រាវមិនបានចុះទៅកំណត់យកទីតាំងភូមិសាស្ត្រតាមផ្កាយរណបដែលបានកំណត់ក្នុងម៉ាស៊ីនកត់ត្រាភូមិសាស្ត្របានឡើយ ព្រោះ មិនអាចទៅបាន ។ បើមានពេល យើងនឹងចុះទៅពិនិត្យផ្ទាល់ឲ្យដល់ទីតាំងតែម្ដងដើម្បីជាការបញ្ជាក់ឲ្យកាន់ តែច្បាស់ថាពិតជាទីតាំងដែលធ្លាប់បានប្រល័យជីវិតមនុស្សអស់រាប់រយនាក់ដោយសារការគោរពបញ្ជាដាច់ខាតមួយពីសំណាក់មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ណាម្នាក់ដែលគ្រប់គ្រងភូមិភាគបូព៌ានេះ ។